Cambodian Buddhist Temple of Canada
7188 De Nancy
MONTREAL, QUEBEC
H3R 2L7, CANADA
Website: www.hoksavann.org
Tel : (514) 735-6901
Fax: (514) 735-6021

ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
វត្តខ្មែរកាណាដា

ថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

<u>កម្មវត្ថុ</u> ៖ សំណើសុំព្រះអន្តរាគមន៍ជួយព្រះសង្ឃខ្មែរកម្ពុជាក្រោម

សូមថ្វាយព្រះពរ,

យោងតាមពត៌មានជាតិនិងអន្តរជាតិបានផ្សាយថា ព្រះសង្ឃខ្មែរកម្ពុជាក្រោមបានត្រូវវៀតណាមចាប់ផ្សឹក ហើយអង្គខ្លះបានជាប់ពន្ធនាគារ និងអង្គខ្លះបាត់ខ្លួន ។ បាតុកម្មបានកើតឡើងជាបន្តបន្ទាប់គ្នារបស់ព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅបរទេស ដូចជានៅសហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី ហើយនៅថ្ងៃសុក្រ២០មេសានេះ បានកើតឡើងនៅភ្នំពេញប្រទេសកម្ពុជា ដែលមានព្រះសង្ឃចំនួន៦០អង្គ បានហែយកញតិទៅជូនទូតវៀតណាម ទាមទារឲ្យដោះលែងព្រះសង្ឃទាំងប៉ុន្មានដែលវៀតណាមបានចាប់ ប៉ុន្តែមិនបានសំរេច ក៏ហែទៅមុខព្រះបរមរាជវាំង និងស្ថានទូតសហរដ្ឋអាមេរិក ។ ក្នុងក្បួនធម្មយាត្រាអហឹង្សា មានសូត្រធម៌ផងនេះ ព្រះសង្ឃ៦អង្គបានត្រូវរបួស ។

សំណើសុំព្រះករុណាមេត្តាជួយធ្វើអន្តរាគមន៍ ចំពោះប្រធានរដ្ឋសភាវៀតណាម ដែលនឹងមកធ្វើទស្សនកិច្ចជាមិត្តភាពនៅប្រទេសកម្ពុជានាថ្ងៃ២៥មេសានេះ សុំឲ្យវៀតណាមបន្ធូរបន្ថយការគាបសង្កត់ មកលើព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរ ហើយសុំឲ្យដោះលែងព្រះសង្ឃដែលវៀតណាមបានចាប់ ។

ជាមួយគ្នានេះ សូមរាជរដ្ឋាភិបាលជួយសម្រួល និងរក្សាសន្តិសុខឲ្យព្រះសង្ឃខ្មែរកម្ពុជាក្រោម បញ្ជេញមតិបានដោយសេរី ស្របតាមរដ្ឋធម្មនុញ្ញ កុំឲ្យកើតមានឧប្បត្តិហេតុដូចថ្ងៃ២០មេសានេះ ព្រោះបាតុកម្មរបស់ព្រះសង្ឃខ្មែរកម្ពុជាក្រោមដូចគ្នានេះនៅបរទេស គេបើកដោយសេរី ហើយគេជួយរក្សាសន្តិសុខយ៉ាងល្អទៀតផង ។

ចំពោះព្រះសង្ឃខ្មែរមួយក្រុមតូច ដែលទៅខាយាំង រហូតប្រើហឹង្សាទៅលើព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលហែក្បួនដោយសន្តិវិធីនេះ តើជាក្រុមណា បំរើអ្វី បានសិទ្ធិខាយាំងនេះមកពីណា តាមការសង្កេត ព្រះសង្ឃខ្មែរកម្ពុជាក្រោមដែលធ្វើនេះ គឺគ្រាន់តែទាមទារគ្នាលោកដែលត្រូវគេធ្វើបាប គ្មានទាក់ទងនឹងព្រះសង្ឃមួយក្រុមតូចនោះទេ ហើយអំពើនោះគ្មានទាស់ខុសនឹងវិន័យបញ្ញត្តិរបស់ព្រះពុទ្ធឡើយ ។ ដូច្នេះបើមិនបានជួយលោកទេ ក៏សូមកុំបៀតបៀនដល់លោកថែមទៀត ព្រោះអ្នកបៀតបៀនគេពុំមានសមណ:អ្នកបួសឡើយ ។

អវសាននេះ សូមព្រះករុណាមានព្រះសុខភាពល្អបរិបូណ៌ ព្រះជន្មយឺនយូរ ។

ព្រះតេជព្រះគុណ ហុក-សាវណ្ណ
វត្តខ្មែរកាណាដា
ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៧